KSI0006

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ករណី មន្ទីរសន្តិសុខ ១៣ (ម-១៣)
## សម្ភាសន៍ជាមួយ ចាន់ វឿន អាយុ៤៩ឆ្នាំ
## ភេទប្រុស រស់នៅភូមិកុមារមាស ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ
## ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៣

**ផ្នែក «ក»**

ឃិនៈ លោកតាឈ្មោះអីដែរ?

វឿនៈ ចាន់ វឿន។

ឃិនៈ អាយុប៉ុន្មានហើយ?

វឿនៈ ៤៩ឆ្នាំ។

ឃិនៈ លោកតាមានប្រពន្ធឈ្មោះអីដែរ?

វឿនៈ ប្រពន្ធឈ្មោះពីរហើយខ្ញុំ។ ប្រពន្ធមុនឈ្មោះ ហង់ តូច។

ឃិនៈ ចុះក្រោយមោ៎?

វឿនៈ ក្រោយ សុះ យឿន។

ឃិនៈ មានកូនប៉ុន្មាននាក់?

វឿនៈ ប្រពន្ធមុនកូន៥។

ឃិនៈ ក្រោយ?

វឿនៈ ក្រោយអត់មាន។

ឃិនៈ ពូសព្វថ្ងៃនៅភូមិអី ឃុំអី ស្រុកអី ខេត្តអី?

វឿនៈ ខ្ញុំ នៅភូមិកុមារមាស ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។

ឃិនៈ លោកតា ឪពុកលោកតាឈ្មោះអីដែរ?

វឿនៈ ចាន់ ឌួង។

ឃិនៈ ម្ដាយ?

វឿនៈ ពែក កោ។

ឃិនៈ បងប្អូនបង្កើតពូមានប៉ុន្មាននាក់?

វឿនៈ មាន៦នាក់ ។

ឃិនៈ ប្រុសប៉ុន្មាន ស្រីប៉ុន្មានដែរ?

វឿនៈ មើល! ១ប៉ក់ ២ឌឿន ៣ម៉ុន ម៉ុច......

ឃិនៈ អរគុណ! ឥឡូវស្រួតមកដល់នេះវិញ ខ្ញុំសួរថាក្នុងសម័យប៉ុលពត សម័យខ្មែរក្រហម ពូរស់នៅទីណា នៅជាមួយអ្នកណា ហើយអាយុប៉ុន្មាន?

វឿនៈ សម័យខ្មែរក្រហម អត់ដឹងអាយុផងខ្ញុំ ។

ឃិនៈ ហើយចុះចលនាដែលគេឲ្យពូចូលទៅធ្វើការហ្មងពូអាយុប៉ុន្មាន?

វឿនៈ អត់ដឹងផង ។

ឃិនៈ ពូនៅជាមួយឪពុកម្ដាយអ្ហេះ?

វឿនៈ អត់ទេ! ខ្ញុំនៅជាមួយទព័ ។

ឃិនៈ អញ្ចឹងមុនដំបូងពូនៅទព័ទេ?

វឿនៈ បាទ!

ឃិនៈ ហើយ អ្នកណាទៅដក?

វឿនៈ ខ្ញុំរត់ចេញពីទព័មៅ គេបញ្ជូនខ្ញុំទៅហ្មងហ្មង ទៅមន្ទីរ១៣ ។

ឃិនៈ រត់ចេញពីទព័?

វឿនៈ បាទ!

ឃិនៈ រត់ទៅណា?

វឿនៈ រត់មៅក្រោយវិញ ។ជំនាន់ហ្នឹង រត់ពីខ្មែរក្រហមចូលមកខ្មែរក្រហម ។

ឃិនៈ រត់មៅក្រោយ នៅត្រង់ណា?

វឿនៈ នៅកុមាររមាសដដែល ។ ប៉ុនគេបញ្ជូនខ្ញុំមកហាត់ហ៊ឹកហ៊ឺននៅអី តាសាយ យើងនេះ តាសាយហាណូយ ។

ឃិនៈ ហាត់ខាងអី?

វឿនៈ ហាត់ខាងបច្ចេកទេសខាងទព័ហ្នឹង ហើយបាន តាឌុច ហ្នឹងគេមៅរើសកងកម្លាំងការពារ ហើយជ្រើសយកខ្ញុំហើយនឹង ជុំ ពីរនាក់ ។

ឃិនៈ ប៉ុន្មាននាក់?

វឿនៈ ២ នាក់

ឃិនៈ ជុំ មួយដែរ?

វឿនៈ បាទ!

ឃិនៈ ជុំ ឥឡូវនៅឯណា?

វឿនៈ អត់ដឹងទេបង បែកគ្នា មិនដឹងស្លាប់ឬ រស់ ។

ឃិនៈ ពេលយកហ្នឹង តើ ឌុច មាននិយាយអីជាមួយលោកពូខ្លះ?

វឿនៈ អត់និយាយអីទេ គ្រាន់ថាកងការពាររើសបានហើយ បានប៉ុន្មាន បានពីរនាក់ ។ ពីរហ្នឹងគេបញ្ជូនខ្ញុំទៅនៅបានម៉ាអាទិត្យ គេចាត់តាំងខ្ញុំឲ្យទៅនៅខាងសេដ្ឋកិច្ច ។

ឃិនៈ សេដ្ឋកិច្ចមន្ទីរ ១៣ ហ្នឹង?

វឿនៈ បាទ! សេដ្ឋកិច្ចមន្ទីរ ១៣ ហ្នឹងឲ្យរកស្រូវរកអង្ករហូតរលាក់កងជើងហ្នុង ។ អត់បាននៅក្នុងទេនៅក្រៅរហូត ។ ខ្ញុំចេះតែដើរៗអញ្ចឹងទៅជាមួយខ្មោចតា កយ ហ្នឹង ។ ដល់ថ្ងៃមួយគេឲ្យខ្ញុំនៅចាំកន្លែងៗ ខ្ញុំឃើញពួកម៉ាកខ្ញុំបីនាក់ ខ្ញុំអង្គុយគិតហ្នុង ហ៊ឺ!មិនគួរយកពួកម៉ាកខ្ញុំមកដាក់គុកអញ្ចឹងអត់កើតទេ ។ រួចគេឲ្យខ្ញុំយាមៗចាំពួកម៉ាកហ្នឹងទៀត ខ្ញុំម៉ោពីរលាក់កងជើងវិញ ។ ខ្ញុំថាតោះអាពួកម៉ាក អ្នែងកាត់ច្រវ៉ាក់រត់ទៅ ចាំអញបាញ់ពីក្រោយ បាញ់ឡើងលើ ។ ដល់អញ្ចឹងវាឲ្យទៅលើកទំនប់ប៉ាំងទឹហ្នឹង ដល់អញ្ចឹងវាកាត់រត់ រត់បានប្រហែលម៉ាសន្ទុះ ខ្ញុំបាញ់៥គ្រាប់ឡើងលើ ។ បាញ់ហើយបានពួកហ្នឹងឡើងឈុល ។ ឈុលម៉ោវាថាមុខសញ្ញាខាងណា អាឌុច វាសួរណាស់ គេថាខាង តាវឿន មើលហៅអាវឿន ម៉ោណេះ អ្នែងទៅដកកាំភ្លើងវា ដោះខោអាវវាទុកតែខោខ្លីទៅបានហើយ ។ ម៉ោដល់ដកកាំភ្លើងមែន ដោះខោអាវអស់អាលីងនៅសល់តែខោខ្លីខ្ញុំ ទៅដល់បញ្ចូលគុក គេចាក់សោរខ្ញុំនេះ គេអត់ទាន់ដាក់ជើងទេ គេនៅចងជាប់កន្លែងមន្ទីរគេ...........ព្រឹកឡើងបានគេបញ្ចូលដាក់ខ្នោះខ្ញុំ ។ ហ្នឹង ឌុច ហ្នឹងណាបង សាហាវណាស់អាហ្នឹង ។

ឃិនៈ បាទ! លោកពូ តើគេដាក់ខ្នោះលោកពូរយៈពេលប៉ុន្មានថ្ងៃ ប៉ុន្មានខែ?

វឿនៈ ដាក់ខ្នោះហ្នឹងបានប្រហែលម៉ាអាទិត្យទេ ។ ដល់ពេលចេញធ្វើការដាក់ច្រវ៉ាក់ករៗ វាយាមផ្ទាល់ដៃវា មានអាការបត់ម៉ាដើម ។

ឃិនៈ ពីណាយាម?

វឿនៈ អា ឌុច ហ្នឹង ។

ឃិនៈ ហើយចុះពេលធ្វើការហ្នឹង ធ្វើតែលោកពូម្នាក់ឬក៏មានអ្នកទោសច្រើនដែរ?

វឿនៈ អ្នកទោសច្រើនដែរ ប៉ុនខ្ញុំថ្ងៃហ្នុងគេយកខ្ញុំទៅតែឯងឲ្យទៅកាប់ដី ។

ឃិនៈ ទៅតែម្នាក់ឯងហ្នឹង? ហើយ ឌុច ហ្នឹងយកអាកាម៉ាដើមយាមតែម្នាក់ឯងហ្នឹង?

វឿនៈ អាការមួយ អង្រឹងមួយ ។ ខ្ញុំគេដាក់ច្រវ៉ាក់ករចងភ្ជាប់ដើមឈើឲ្យកាប់ដី ។ រួច ឌុច វ៉ាយាម ។ បានប្រហែលអញ្ចឹងទៅ ខ្ញុំអត់រស់ទេ មុខតែស្លាប់ហើយខ្ញុំ អត់កើត ដល់អញ្ចឹងទៅចូលទៅក្នុងគុកវិញ ខ្ញុំគិតជាមួយ ខន ។

យិនៈ យប់បញ្ចូលពូទៅក្នុងគុកវិញ?

វឿនៈ បាទ! បញ្ចូលក្នុងគុកវិញ ដល់ពេលអញ្ចឹងខ្ញុំគិតជាមួយ អាខន ។ អាខន ហ្នឹងវ៉ាត្រូវសាច់ថ្លៃខ្ញុំដែរ ខ្ញុំថាអា ខន ថ្ងៃហ្នឹងអញរត់ហើយ អ្ហែងធ្វើម៉េចដោះករជើងអញរត់ហើយយប់ហ្នឹង ។ អាខន វ៉ាថាអត់អីទេពូ ពូឯងរត់ចេះ ហើយយប់ឡើងខ្ញុំរត់មែន ។ រត់មៅៗដល់............លួអំពៅគាត់អស់ប្រាំដើមទៀត ខ្ញុំឃ្លានពេក ។ ពេលដាក់គុកហ្នឹងគេឲ្យហូបបបរតិចៗ ។ ដល់អញ្ចឹងក៏បានប្រហែលម៉ាអាទិត្យដាង ក៏ប្រធានភូមិគេធានាខ្ញុំថា គេហៅវឿន ឯងទៅវិញហើយ ។ ដល់ទៅវិញខ្ញុំភ័យណាស់ មុខជាងាបហើយពេលហ្នឹងអត់រស់ ។ គេថាទៅ ខ្ញុំធានា កាលហ្នឹងខ្មោចតា ហម និងតាសោម យើងនេះ ។ គាត់ថាទៅអត់អីទេ ខ្ញុំធានា ។ ទៅដល់អត់អីមែន ខ្ញុំគិតថាកាំភ្លើងខ្ចីវ៉ាហ្នឹងប៉េះកណ្ដាលថ្ងាស់លើវ៉ាលហ្នឹងហើយ ខ្ញុំអង្គុយនៅលើ......ហ្នឹង ។ វ៉ាថាអ្ហែងរត់ទៅអត់អីទេនៅហ្នឹងហើយ អ្ហែងនៅហ្នឹងសិនហើយ ។

យិនៈ គេឲ្យធ្វើអីទៀតក្រោយអាពេលដែលគេយកទៅ?

វឿនៈ បាទ! អត់មានឲ្យធ្វើអីទេ ។ ប៉ុនថាឲ្យនៅហ្នឹងហើយ ឲ្យបាននៅជាជាងកន្លះខែ បានឃើញក្រដាសចេញមៅថាឲ្យខ្ញុំចេញ ។

យិនៈ ឲ្យចេញ?

វឿនៈ បាទ! ឲ្យចេញហ្នឹងខ្ញុំភ័យទៀត ហ៊ឺ! មិនដឹងជាក្រដាសខៀវ ឬក្រដាសក្រហមទេ ។ បើក្រហមមុខជាងាប់ហើយ ។

យិនៈ ក្រដាសក្រហមបានន័យថាម៉េច អក្សរអី?

វឿនៈ បើក្រហមថាងាប់ ។

យិនៈ ប៊ិចក្រហមអ្ហេះ?

វឿនៈ បាទ! ប៊ិចក្រហម ។ ដល់អញ្ចឹងខ្ញុំសុំ អាហ៊ំ មើល ។ អាហ៊ំ អញសុំក្រដាសអ្ហែងមើលបន្តិចអាហ៊ំ ហ្នឹងក៏ឲ្យខ្ញុំមើល ។ មើលទៅឃើញខៀវទេ អ្ហូ! មានឧបាយកលអីទៀតអពេះ! គេបញ្ជូនខ្ញុំមៅដល់ស្ពានអី អូរពន្ធក អូរអើបង! ស្ពានថ្មគុបនេះ អូរ(នុបពពក) ក៏បានស្នាក់ការគេថា ឥឡូវពូឯងទៅផ្ទះទៅអត់អីទេ ។ ទេ! អត់ទុកចិត្តទេ បងជូនខ្ញុំទៅ សាលាយើងនៅកន្លែងស្រុកនេះ គាត់ធ្វើការហ្នឹង គាត់ថាទៅៗអត់អីទេ មានក្រដាសហ្នឹងហើយអត់អីទេ ក៏ខ្ញុំមៅ ។

បុិនសភាពនៅក្នុងមន្ទីរហ្នឹង តាឌុច ហ្នឹងឃោរឃៅណាស់ ។ មិនត្រឹមតែអ្នកទោសទេ ដូចខ្ញុំថា អញ្ចឹងសូម្បីកងការពារដែលធ្វើការជាមួយគាត់ ដែលធ្លាប់វ៉ៃអ្នកទោសសួរចម្លើយក៏គាត់សម្លាប់ដែរ មានដូចផល ហ្នឹង មាន ប៉ុន ហ្នឹង សុទ្ធតែអ្នកដែលធ្លាប់វ៉ៃអ្នកទោសសួរចមើយដែរ យូរៗទៅៗជាគេវ៉ៃគាត់ចោលអស់ដែរ ។ ពេទ្យ សំ នេះអញ្ចឹងដែរ ។

ឃិនៈ ពេទ្យឈ្មោះអីដែរ?

វឿនៈ ពេទ្យ សំ ។

ឃិនៈ គាត់ខុសអី?

វឿនៈ អត់មានខុសអីទេ ដែលយូរៗទៅ ថាគាត់អីណាណីវ៉ៃគាត់ចោលបាត់ទៀតទៅ ។

ឃិនៈ អាហ្នឹងអ្នកដែលធ្វើការជាមួយគាត់?

វឿនៈ បាទ! អ្នកដែលធ្វើការជាមួយគាត់ ដូច ប៉ុនអីហ្នឹង ។

ឃិនៈ ចុះអ្នកដទៃដែលគាត់មានដែលបានសួរចម្លើយផ្ទាល់ទេ?

វឿនៈ សួរខ្ញុំអ្ហេះ?

ឃិនៈ ទេ! សួរអ្នកដទៃ ។

វឿនៈ សួរអ្នកដទៃ សួរដែរ ។ សួរវ៉ៃ ហើយដើរដុតទៀតណោះ អាណាមិនស្រែកដុត ស្ទោកខ្ទេចខ្ទីរអស់ហើយ ។ រឿងនេះដាក់ស្តែងពិតអញ្ចឹងហ្មង ដាក់ស្តែងពិតអញ្ចឹងហ្មង កាចណាស់ បើថាវាចង់បាញ់អាណាបាញ់អាហ្នឹងហើយ ។

ឃិនៈ ចុះពូនិយាយមុនពេលសម្ភាសន៍ថាមានឃើញ ឌុច ហ្នឹងបាញ់ផ្ទាល់ដៃប៉ុន្មាននាក់?

វឿនៈ ឃើញបាញ់ផ្ទាល់មួយ ។

ឃិនៈ បាញ់កាំភ្លើងខ្លីអី?

វឿនៈ បាញ់អាការ ។

ឃិនៈ ហ្នុងអ្នកទោសប្រុសស្អី?

វឿនៈ អ្នកទោស ។ បាញ់អ្នកទោស ខឹងសួរអត់ចេញបាញ់.............បាញ់បីគ្រាប់ ប៉ុនមិនដឹងឈ្មោះអីខ្ញុំ មិនស្គាល់ឈ្មោះដែរណាស់ ។

រ៉ាស៊ីៈ ពូខ្ញុំចង់សួរពូសារដើមឡើងវិញបន្តិចណាពូណាស់?

វឿនៈ បាទ!

រ៉ាស៊ីៈ ពូចូលធ្វើទាហានតាំងពីឆ្នាំណា?

វឿនៈ ទាហានយើងអី ។

រ៉ាស៊ីៈ ទាហានខ្មែរក្រហមនៅមន្ទីរ ១៣?

វឿនៈ ១៩៧០ខ្ញុំនៅផ្តល់ជាតិលេខ៥ ដល់ខ្ញុំវាវៃបាក់ទៅខ្ញុំខ្លាច ខ្ញុំរត់មកក្រោយវិញ។ ដល់រត់មកក្រោយហ្នឹង ក៏គេរើសកម្លាំងទៅនោះ ខ្ញុំអត់ដឹងទេ គេថារើសកម្លាំងពីរនាក់ហាត់របៀបទព័សង្គ្រាមហ្នឹង។ ហាត់ៗក៏បញ្ជូនខ្ញុំទៅក្នុងបាត់ទៅ។

រ៉ាស៊ីៈ ទាហានដែលពួចូលហ្នឹង ទាហានលន់ ណុល ឬទាហានខាងខ្មែរក្រហម?

វឿនៈ ខាងខ្មែរក្រហម។

រ៉ាស៊ីៈ អ្នកណាដែលជ្រើសរើសពូចូល?

វឿនៈ ជ្រើសរើស តាឌុន ហាណូយ។

រ៉ាស៊ីៈ ម៉េចបានគេហៅ តាឌុន ហាណូយ?

វឿនៈ ចុះបើគាត់មកពីហាណូយ។ ប៉ុនគាត់ហ្នឹងក៏ស្លាប់ដែរហើយ។

រ៉ាស៊ីៈ នៅពេលដែលពូចូលអញ្ចឹង នៅក្នុងឃុំអមលាំងយើងនេះ មានបង្កើតជាមន្ទីរសន្តិសុខអីនៅ?

វឿនៈ មាននៅហ្នុងហ្នង មាននៅមន្ទីរ ១៣ ហ្នង។

រ៉ាស៊ីៈ អញ្ចឹងមន្ទីរ ១៣ ហ្នឹងមិនមែនមានតាំងពីឆ្នាំ១៩៧២មកទេអញ្ចឹង?

វឿនៈ មិនដឹងមានពីឆ្នាំប៉ុន្មាន បើខ្ញុំចូលទៅឃើញខ្ញុំឡើង អូរ! អត់កើតទេដល់ឃើញអញ្ចឹង ភ័យខ្លួនហ្នង វាមិនដែលឃើញ។

រ៉ាស៊ីៈ ហើយនៅក្នុងឆ្នាំណាដែលពូមានប្រសាសន៍ថា ឌុច បានមកហៅពូមកនៅក្នុងមន្ទីរ ១៣អ្នកស្រាវដែលគេជ្រើសរើសយកតែពីរនាក់មក?

វឿនៈ ១៩៧៣។ បាទ! ចាំ ៧៣។

រ៉ាស៊ីៈ ហ្នឹង ឌុច ហៅមកអ្ហេះ?

វឿនៈ ឌុច គេគ្រាន់តែជ្រើសរើសទេ ប៉ុនមានគេណេះអ្នករើស។ តាឌុន ហាណូយហ្នឹងអ្នករើស។ គ្រាន់តែរើសបានហើយ ហាត់រៀនបានតែ៦ថ្ងៃ បញ្ជូនខ្ញុំទៅហ្នុង។

រ៉ាស៊ីៈ ពេលដែលរើសឈ្មោះពូបានហើយ គេយកពូទៅរៀនសិន?

វឿនៈ អត់ទេ! គេនៅបង្ហាត់ហ្នឹង ពួកហាណូយគេបង្ហាត់ហ្នឹង។ ហាត់បានតែ៦ថ្ងៃ គេបញ្ជូនទៅហ្នុងហ្នង។

រ៉ាស៊ីៈ ហើយម៉េចបានគ្នាមកគំនរ បែជាជ្រើសរើសតែពូហើយហ្នឹងពួកមកពូអញ្ចឹង?

វឿនៈ ខ្ញុំអត់ដឹងដែរ បើគេរើសយកតែពីរនាក់ៗ បើគេកម្លាំងនោះនៅខុះកម្លាំងពីរនាក់។

រ៉ាស៊ីៈ អញ្ចឹងចំពោះពូ និងមិត្តភក្រ័ពូម្នាក់ទៀត បានន័យថាជាកម្លាំងមួយពិសេសក្នុងចំណោមកម្លាំងដែលពូហាត់ជាមួយហ្នឹងមែនទេ?

វឿនៈ បាទ! ហាត់ជាមួយគ្នា ។ ហាត់ហើយចេញទៅហ្មង ។

រ៉ាស៊ីៈ ឥឡូវនៅពេលដែលពូចូលទៅដល់មន្ទីរ១៣ តើពូឃើញអ៊ីមុនដំបូងគេ?

វឿនៈ ទៅដល់ឃើញតែអ្នកទោសដែលគេចងរដូករណែល ខ្សែអង្រឹង ហើយខ្ញុំនេះវាមិនដែលឃើញខ្លះស្រាតខោស្រាតអាវអស់អញ្ចឹង ខ្ញុំឡើងចង់បាត់ព្រលឹងអស់ហើយ ។ មនុស្សវាអត់ដែលឃើញបាទ! ។ ទៅដល់ខ្ញុំដល់ហើយ តែមិនដឹងធ្វើម៉េចបើមនុស្សគេយកទៅហើយ ។ ឲ្យយកទៅទៅ បានប្រហែល២០ថ្ងៃ គេក៏ចាត់កម្លាំងខ្ញុំថា វឿន ឯងឥឡូវខ្ញុំឲ្យនៅខាងសេដ្ឋកិច្ច ដើររកអង្ករកស្រូវឲ្យអ្នកទោស ។ អាក្រណាត់អង្រឹងយើងហ្នឹង អានីឡុងយើងហ្នឹងយកទៅដូរស្រូវ ។ ដល់ដើរដូរស្រូវដូរអីទៅ យើងខ្ញុំមោចូលកន្លែងម្តងៗ ឃើញតែទារុណកម្មអ្នកទោសលាន់ទ្រហោមិនដឹងជាស្អីៗទេបងអ៊ើយបងអ៊ើយពិបាកមើលណាស់ ។

រ៉ាស៊ីៈ ពេលដែលពូចូលទៅ តើចូលទៅជាមួយនរណាគេ?

វឿនៈ ចូលទៅជាមួយ ជុំ ហ្នឹង ។ ជុំ ហើយនៅខាងក្រាំងចំបក់ ប៉ុនឥឡូវមិនដឹងទៅណាទេអត់ដែលជួបគ្នាសោះ មិនដឹងស្លាប់ ឬរស់ នៅជាប់ជាមួយ ឌុច អត់ ។

រ៉ាស៊ីៈ ភូមិអី?

វឿនៈ ក្រាំងចំបក់

រ៉ាស៊ីៈ ឃុំ?

វឿនៈ ឃុំអមលាំងដែរ នេះត្រង់ណេះហ្នឹង ។

រ៉ាស៊ីៈ ពូទៅធ្វើជាកងការពារនៅហ្នឹងអេ្ហះ?

វឿនៈ បាទ! ទៅដល់គេឲ្យនៅកងការពារ ប៉ុនគេមិនទាន់ឲ្យយាមអ្នកទោសភ្លាមទេ ទៅដល់គេនៅផ្សាំយើងបន្តិចសិន ។

រ៉ាស៊ីៈ បាទ! ឌុច ហ្នឹងមានមោប្រាប់ពូថាម៉េចទេ?

វឿនៈ ឌុច ហ្នឹងគ្រាន់ថាខ្វះកងកម្លាំងការពារ អ្ហែងទៅនៅជួយការពារនោះសិនទៅ ។ នៅបានប្រហែលជាងមោអាទិត្យ បានគេចាត់តាំងខ្ញុំឲ្យមោនៅខាងសេដ្ឋកិច្ចវិញ ។ បាទ! តែខ្ញុំមួយទេ ហើយហ្នឹងតាសយ ឥឡូវគាត់ស្លាប់បាត់ហើយ ។ តាសយ នៅផ្ទះ តែពីរនាក់តា សយ ហ្នឹងទេ ។

រ៉ាស៊ីៈ ចុះកងការពារអ្នកទោស ក្រែងពូធ្លាប់ធ្វើដែរអេ្ហះ?

វឿនៈ ធ្មើ! គ្រាន់កម្លាំងខ្ញុំមួយគេឲ្យចេញក្រៅ គ្រាន់តែដើររកស្បៀងឲ្យអ្នកទោស។ ដូចខ្ញុំនិយាយថា មានបងប្អូននិងអ្នកជាប់ទោសអញ្ចឹង គេធ្វើបាយ ធ្វើនំអីអញ្ចឹងទៅ អត់ហ៊ានឲ្យ ឌុច ហ្នឹងដឹងទេ យកទៅលាក់ក្នុងព្រៃចន្រ្ទីបានបញ្ចេញយកទៅឲ្យអ្នកទោស។ ដូច អ៊ីន ពួកម៉ាកខ្ញុំសួរមើលចុះ។ ខ្ញុំបញ្ចេញយកឲ្យវា ថ្នាំជក់អី បាយ នំកន្ទក់ក៏ដោយ។ មានតែនំកន្ទក់ទេ ហើយតែឲ្យគេដឹងងាប់ ហើយគ្មានរស់ទេ។

រ៉ាស៊ីៈ ពូខ្ញុំចង់កងការពារនៅក្នុងមន្ទីរ១៣ ហ្នឹងតើមានបែងចែកជាក្រុម បែងចែកជាវរសេនាតូច ឬកងអីទេ?

វឿនៈ មានបែងចែក។

រ៉ាស៊ីៈ បែងចែកយ៉ាងម៉េច?

វឿនៈ បែងចែកជា ១)កម្លាំងកងការពារអ្នកទោសធ្វើការពេលថ្ងៃ។ កម្លាំងទី២)ជាជនចម្រើនរបស់គេនោះ ដៃស្តាំរបស់គេហ្នឹងណា។ អាហ្នឹងគេសម្រាប់មានការអី យកមនុស្សទៅសម្លាប់ត្រង់ណាត្រង់ណីអីហ្នឹង អាហ្នឹងមានកម្លាំងផ្សេងរបស់គេទៅ។ កងការពារគឺគ្រាន់តែការពារអ្នកទោសកុំឲ្យរត់ទេ។ ដូចខ្ញុំអីហ្នឹងគ្រាន់តែកងការពារធ្វើការពេលថ្ងៃអីមើលអ្នកទោសកុំឲ្យរត់ចេញទេ។

រ៉ាស៊ីៈ បើតាមខ្ញុំសម្ភាសន៍ឈ្មោះ ឌិន ដែលពូបានស្គាល់ដែរនោះ គាត់ថាគាត់នៅក្នុងកងការពារដែរ តែគាត់នៅក្នុងក្រុមមើលអ្នកទោសធ្វើការ តើគាត់និយាយហ្នឹងពិតទេលោកពូ?

វឿនៈ ខ្ញុំអ្ហេះ?

រ៉ាស៊ីៈ អត់ទេ! ពូ ឌិន ណាស់។

វឿនៈ ឌិន ហ្នឹងគាត់នៅកុមារ គ្រាន់តែគាត់នៅការពារអ្នកទោស។

រ៉ាស៊ីៈ ប៉ុន្តែគាត់ថាគាត់ជាអ្នកយាមអ្នកទោសធ្វើការ?

វឿនៈ ហ្នឹងហើយគ្រាន់តែយាមអ្នកទោសពេលធ្វើការទេ ឌិន ហ្នឹងនោះ។

រ៉ាស៊ីៈ ហើយគាត់បាននិយាយទៀតថា មានក្រុមគ្នាគាត់មួយទៀតនោះ គឺយាមអ្នកទោសពេលសួរចម្លើយ ពេលអ្នកទោសជាប់ឃុំឃាំង តើអាហ្នឹងត្រូវទេ?

វឿនៈ ត្រូវ។

រ៉ាស៊ីៈ មានអញ្ចឹងមែនពូអ្ហេះ?

វឿនៈ មាន! មានបែងចែកកម្លាំងពីរផ្នែក។

រ៉ាស៊ីៈ អញ្ចឹងពីរផ្នែកដែលពូនិយាយម៉ិញថា កងការពារអ្នកទោស និងជនចម្រើន បានន័យថាក្នុងមួយៗហ្នឹងត្រូវបែងចែកជាកងផ្សេងៗទៀត?

វឿនៈ បាទ! កងផ្សេងៗពីគ្នា ។ ១) កងការពារអ្នកទោសកុំឲ្យរត់ ដូចយើងធ្វើការពេលថ្ងៃយាម ។ មួយទៀតសួរចម្លើយអ្នកទោស ក្នុងកងការពារគេដែរ ។ គេបែងចែកកម្លាំងពីរអញ្ចឹង ។

រ៉ាស៊ីៈ ចុះជនចម្រើន?

វឿនៈ ជនចម្រើន គឺដៃស្តាំរបស់គេហ្នុង អាហ្នឹងអ្នកវៃ អ្នកធ្វើទោសសួរចម្លើយហើយ ។ អាហ្នឹងនៅលើ ឌុច ជាអ្នកបញ្ជា ។ ដូចថារូបខ្ញុំ ឬរូបអ៊ំអញ្ចឹង បើថាឲ្យវៃសួរចម្លើយ បើថាសួរមិនចេញយកបាញ់ចោល គឺ ឌុច ហ្នឹងជាអ្នកបញ្ជាហើយ ។

រ៉ាស៊ីៈ អញ្ចឹងសរុបទាំងអស់ តើកងការពារ និងជនចម្រើនមានគ្នាប៉ុន្មាននាក់ដែរក្នុងមន្ទីរ១៣ហ្នឹង?

វឿនៈ កាលដែលខ្ញុំនៅហ្នុងមានគ្នា ១៥ នាក់ ប៉ុនខ្ញុំមិនស្គាល់ឈ្មោះអស់ទេបង ស្គាល់តែ ឡុញ ស្គាល់ តែ សឿន.......... ជុំ ខ្ញុំ សយ ណិន ។ ណិន យើងមួយដែរនៅ........ ។ អាខន ខនហ្នឹងគេអ្នកហ្នឹងហើយ ។

រ៉ាស៊ីៈ ខន ដែលថានៅស្អីក្បាលចិនហ្នឹងអេ្ហះ?

វឿនៈ បាទ! ហ្នឹងហើយ ។ ខន គេខាងកុមារ ប៉ុនកុមារហ្នឹង កុមារអស់ទាស់ហើយ គ្រាន់តែតាវាក៏ដាក់ដែរអាហ្នឹងនោះ ។ ខ្ញុំដឹងប៉ុណ្ណឹងណា ។

រ៉ាស៊ីៈ បាទ!

វឿនៈ ប៉ុន្តែសកម្មភាពរបស់ ឌុច ដូចខ្ញុំរៀបរាប់អញ្ចឹងថា ។

រ៉ាស៊ីៈ ហើយពូស្គាល់ពូ អ៊ុន តាំងពីពេលណាដែរ?

វឿនៈ អ៊ុន ហ្នឹងកាលដែលខ្ញុំទៅហ្នឹង ឃើញនៅហ្នុងហ្នុង ។

ឃិនៈ អ៊ុន ជាប់មុនអញ្ចឹង?

វឿនៈ បាទ! អ៊ុន ជាប់មុន ។ ខ្ញុំថាអុញ អានេះពួកម៉ាកខ្ញុំតើ ប៉ុនខ្ញុំដឹងថា ចុះបើនៅក្នុងឃុំ ជាមួយគ្នា ប៉ុនខ្ញុំអត់ហ៊ានមាត់ទេ កាលណាខ្ញុំនិយាយទៅនាំឲ្យវាត្រូវអ្នកទោសទាំងអស់គ្នា ។ ប៉ុន អ៊ុន ហ្នឹង គេសម្រាលទោសហើយ ។ មុនដំបូងគេចង គេសួរចម្លើយដែរ ឌុច ហ្នឹង ដល់ហើយគេសម្រាលទោស អ៊ុន ពួកម៉ាកខ្ញុំហ្នឹង ហើយ អ៊ុន នឹងខ្ញុំហ្នឹងកម្សត់កម្រពីរបីដងហើយ បិះងាប់ទៀត ។ ថ្ងៃមួយខ្ញុំបបួលវាទៅដេញឈ្លូស ចាំសួរវាមើល ។ ដេញឈ្លូសទៅចំអាកន្លែងដែលគេលាក់ការវៃមនុស្សចោល ខ្ញុំមានដឹងឯណា ដល់ខ្ញុំមិនដែលចេញក្រៅ មិនដែលឃើញគេវៃមនុស្សចោល ទៅដល់ហៅ អ៊ុន ហ្នឹងមួយ និងប៉ុន្មាននាក់ដែលដាក់ទោសស្រាល ៥-៦នាក់ដែលគេសម្រាលទោសដូច អ៊ុន ហ្នឹង ។ នាំគ្នាដើរៗ អាឌុច ថា ចុះអាណាទៅណា?! គេថា បងវឿន ។ មើល៍

ហៅអាវឿន ម៉ៅនេះមើលម៉េចទៅកន្លែងហ្នឹង ទៅដល់ហ្នឹង ទៅពិនិត្យមើលខ្មោចស្លាប់ក្នុងរណ្ដៅ ខ្ញុំអត់មានដឹងថាកន្លែងវ៉ៃមនុស្សចោល ។

ឃិនៈ ក្នុងវត្តមន្ទីរ១៣ ហ្នឹង?

វឿនៈ បាទ! ក្នុងមន្ទីរ១៣ ហ្នឹង ។ ខ្ញុំហើយអា អ៊ីន ភ្ញាក់ខ្លួនព្រឹត អីយ៉ាអាអ៊ីន តាឌុច វ៉ៃមនុស្សចោលច្រើនម៉េះអ្ហក្នុងរណ្ដៅហ្នឹង ។

រ៉ាស៊ីៈ ម៉េចដឹងតា ឌុច វ៉ៃ?

វឿនៈ ចុះបើកន្លែងវាហ្នឹង មានពីណាមៅបង បើអ្នកទោសបញ្ជូនៗមៅ ស្រាប់តែឃើញនៅក្នុងរណ្ដៅណោះ ។ ឯខ្ញុំនេះក៏វាហៅមៅថាម៉េច វឿន ឯងម៉េចក៏នាំអ្នកទោសទៅអញ្ចឹង ។ ខ្ញុំថា ខ្ញុំអត់ដឹងទេបង ខ្ញុំរត់ដេញឈ្លួស ។ ចាំសួរ អ៊ីន ពួកម៉ាកខ្ញុំហ្នឹងមើល៍ ។ ហ្នឹងរឿងម្ដង រឿងម្ដងទៀត ឃ្លានបាយពេក នាំអ្នកទោសមៅហូបបាយនេះនៅភូមិថ្នគុបនេះ មៅរករឿងខ្ញុំអីណាណី តាឌុច ហ្នឹងប្រុងបាញ់ខ្ញុំចោលទៀតណោះ កុំបាន ប៉ុន និងផល ហ្នឹងនិយាយថា គួរអនុគ្រោះឲ្យខ្ញុំម្ដងទៅ ។ គេថាខ្ញុំហ្នឹងម៉េច ដល់យប់ហ្នឹងសកម្មភាពម៉េច ម្សែងហ្នឹងធ្វើយ៉ាងម៉េចបានដើរទាល់យប់អញ្ចឹង? ប៉ុនខ្ញុំនាំពួកម៉ាកខ្ញុំ ខ្ញុំឃ្លានពេកនាំដាំបាយនៅថ្នគុបនេះ សុំបាយប្រជាជនឲ្យហូប ខ្ញុំអស់ប៉ុណ្ណឹងហើយ ។ ឌុច ហ្នឹងរករឿងចង់បាញ់ខ្ញុំចោល សួរទៅសួរពួកម៉ាកខ្ញុំទៅ ។

ឃិនៈ បាន ផល ហើយហ្នឹង ប៉ុន ហ្នឹងអង្វរ?

វឿនៈ បាទ! ផល និង ប៉ុន ថាគួរអនុគ្រោះឲ្យគាត់ម្ដងទៅ បើធ្វើម៉េចទេ កុំរកបាញ់រកអីគាត់ចោលអញ្ចឹង ។ ឌុច ថាបាញ់ចោលអាហ្នឹងអត់កើតទេ នាំអ្នកទោសរត់ ។ អាកន្លែងដេញឈ្លួសនេះក៏ធ្ងន់ណាស់ដែរ ។

រ៉ាស៊ីៈ ពួអាកងការពារហ្នឹងមានវិន័យម៉េចដែរ គេដាក់វិន័យម៉េចដែរ?

វឿនៈ វិន័យ! ដូចខ្ញុំថាវិន័យដូចអត់មានអីគឹងទេ បើថាកងការពារ អ្នកទោសចេញទៅធ្វើការ បើដូចថាឈ្មោះខ្ញុំអញ្ចឹង ៥ ៦នាក់ឲ្យយាម គឺយាមហើយ ។ អ្នកឯងឲ្យរួចគឺទទួលខុសត្រូវហើយ ដូចខ្ញុំអញ្ចឹង ខ្ញុំលែងពួកម៉ាកខ្ញុំបីនាក់អញ្ចឹងគ្រាន់តែលែងភ្លាម ម៉ៅដោះខោដោះអាវខ្ញុំអស់អាលីងដកកាំភ្លើងនៅសល់តែខោខ្លីទេបង ។

រ៉ាស៊ីៈ ពូលែងពីណាគេខ្លះ? ឈ្មោះអីខ្លះដែរ?

វឿនៈ ឈ្មោះ រត្ន័ មួយ ។ រត្ន័ នៅសំរោងនេះ ។

រ៉ាស៊ីៈ សព្វថ្ងៃនៅរស់ទេ?

វឿនៈ អត់ដែលជួបផង តាំងពីលែងមៅមិនដឹងជាស្លាប់ ឬរស់បីនាក់ហ្នឹង ហើយពីរនាក់នោះភ្លេចឈ្មោះហើយ ប៉ុនលែងបីថ្ងៃហ្នុង សុទ្ធតែគ្នាខ្ញុំ បើធ្លាប់ជួបមុខគ្នា ធ្លាប់ដើរលេងជិនាន់នោះ ។

ភាស៊ីៈ ចុះម៉េចបានជាពូមានសិទ្ធទៅដោះលែងអ្នកទោសនៅហ្នុង?

វឿនៈ ខ្ញុំអាណិត ខ្ញុំសុខចិត្តខ្ញុំចូលគុក ។ បើសុទ្ធតែពួកម៉ាកទៅហើយ ទុកដូចជាបងប្អូនបង្កើតស្រឡាញ់គ្នាកាលពីជិនាន់អាពតមៅ ជួបមុខគ្នានោះដល់យកមកដាក់គុកអញ្ចឹងអត់កើតទេ ។ សុខចិត្តឲ្យជាប់គុកខ្ញុំចុះ កុំឲ្យ ។

ភាស៊ីៈ ហ្នឹងនៅក្នុងឆ្នាំណាដែរ?

វឿនៈ ៧៣ ហ្នឹង ។

ភាស៊ីៈ ខែណាមានចាំទេ?

វឿនៈ អត់ចាំខែទេបង ។

ភាស៊ីៈ ពេលដែលពូដោះលែងអ្នកទាំងបីហ្នឹង ឌុច នៅឯណាដែរ?

វឿនៈ ឌុច នៅក្នុងមន្ទីរ ។

ភាស៊ីៈ ប៉ុន្តែអត់ដឹងទេ?

វឿនៈ អត់ដឹងទេ បើថាឲ្យខ្ញុំយកអ្នកទោសបីនាក់ហ្នឹងយកទៅយាមលើកទំនប់ ឲ្យខ្ញុំអង្គុយយាមហ្នឹងដល់ខ្ញុំថា វាថាអាពួកម៉ាក អាមួយថាពួកម៉ាក អាមួយថាបង ។ វាថាឲ្យខ្ញុំរត់ទៅបងអើយមើលទៅអត់កើតទេ ។ ខ្ញុំថាគោះរត់ៗទៅ អ្ហែងនឹងអញវាអស់សាច់ឈាមគ្នា គោះអញសុខចិត្តចូលគុក ។ ខ្ញុំថាអញ្ចឹង ប៉ុនអ្ហែងរត់ អញអត់ទាន់បាញ់អ្ហែងទេ អ្ហែងរត់ឲ្យផុតសិនទៅ ។ អានោះរត់ផុតបាត់ស្រមោលវាទៅក្នុងព្រៃតែហ្នង ។ អង្គុយៗទៅគ្រាន់តែបាត់ស្រមោលវា ខ្ញុំបាញ់ឡើងលើ៩គ្រាប់ ប៉ុង១១ គ្នាវាផ្អើលឈុលមៅថា អ្ហកអ្នកទោសរួចហើយ ។ គ្រាន់តែឮបាញ់ដឹងថាអ្នកទោសរួចហើយ ។ ឌុច មៅសួរខ្ញុំ ខ្ញុំថាបងអើយអ្នកទោសរួចហើយ ធ្វើម៉េចខ្ញុំលក់ម៉ាកាំង ប៉ុនអត់ទេ ។ ខបាយកលខ្ញុំថាធ្វើម៉េចឲ្យពួកម៉ាករត់បានរួចចោះ ។

ឃិនៈ ប៉ុនអ្នកទោសមានដាក់ច្រវ៉ាក់ទេ?

វឿនៈ អាម្នាក់ទៀតខ្ញុំអត់ស្គាល់ទេ ។ ប៉ុនបីនាក់ ពួកម៉ាកខ្ញុំតែពីរនាក់ទេ រត្ន័ នោះមួយ ហើយមួយទៀតខ្ញុំភ្លេចបាត់ហើយ ។ ម្នាក់នោះធ្វើម៉េចដោះពីរមិនកើត ដោះបីតែម្តងទៅ ឲ្យទៅទាំងអស់ទៅ ។

ឃិនៈ អ្នកទោសនោះមានដាក់ច្រវ៉ាក់ដែរ?

វឿនៈ ដាក់ៗ ប៉ុនពូថៅគ្រប់ដៃទាំងអស់ៗ ទៅដល់ខ្ញុំផ្អែកកាំភ្លើងអញ្ចឹងជួយដាប់វាហ្នឹងៗ ដាប់ផ្ទប់ឈើអត់ដាច់ ទាល់តែដាក់ផ្ទាប់ថ្មបានដាច់ៗ ពូថៅដាក់ប៉ិច ដាក់លើថ្មៗ ខ្ញុំថាអាពួកម៉ាកអ្នែងធ្វើម៉េចឲ្យតែរួចទៅ អញ ចាំអញបាញ់តាមក្រោយឲ្យផ្អើលអ្នែងចាំមើល រត់រួចឲ្យឆ្ងាយសិនទៅៗ

វ៉ាស៊ីៈ ដល់ពេល ឌុច ដឹង ឌុច ព្រមានពូថាម៉េចខ្លះទៅ?

វឿនៈ ព្រមានដូចខ្ញុំថាអញ្ចឹង គាត់ថាអ្នកទោសរួចខាងណា ខ្ញុំថារួចខាងបង វឿន អាពួកនៅខាងក្នុងណាស់ ខ្ញុំថារួចខាងខ្ញុំហើយៗ ឥឡូវអ្នែងទៅដកកាំភ្លើងអា វឿន ចេញ ហើយដោះខោដោះអាវវាឲ្យអស់ ហើយហៅវាមៅចូលគុកៗ បងអ៊ើយ! ទៅដល់ចូលគុកភ្លក គុកឫស្សីយើង អាគុកកន្លែងប្អូនជ្រុងយើងនោះ ទៅដល់ខ្សែករខ្ញុំវ៉ាប់ តែអត់ទាន់វ៉ៃទេៗ ទោសខ្ញុំមិនដល់ថ្នាក់វ៉ៃទេគ្រាន់តែលួចអញ្ចឹងគេចាក់សោរខ្ញុំចង់ភ្ជាប់ឫស្សីអញ្ចឹង នៅហ្នឹងៗ បានម៉ាអាទិត្យ វាបណ្តើរខ្ញុំចេញទៅធ្វើការខ្ទួនវា អាការម៉ាដើមចាក់សោរខ្ញុំវ៉ាប់បណ្តើរកាប់ដី ចងភ្ជាប់ដើមឈើអញ្ចឹង វាបន្ធាយខ្សែរឲ្យវែងអញ្ចឹងទៅឲ្យកាប់ដីៗ

ឃិនៈ ចេះតែកាប់ដីទៅ?

វឿនៈ បាទ! ចេះតែកាប់ដីទៅ ឈប់អត់បានទេៗ ឈប់វាស្រែក ម៉េច!ៗ

ឃិនៈ កាប់ធ្វើអីដីហ្នឹង?

វឿនៈ វាចេះតែឲ្យកាប់ទៅ

វ៉ាស៊ីៈ ហើយច្រវ៉ាក់ហ្នឹងឃ្លាតពីដើមឈើប៉ុន្មាន ចម្ងាយណាច្រវ៉ាក់?

វឿនៈ ខ្សែអង្រឹងទេ មិនមែនច្រវ៉ាក់ទេៗ ខ្សែអង្រឹងទាក់ករៗ ទោះជារត់ក៏រត់អត់រួចទេ បាញ់ងាប់ឥឡូវ បើវានៅយោលអង្រឹងអញ្ចឹង វាបែរកាណុងចំខ្ញុំអញ្ចឹងៗ

វ៉ាស៊ីៈ ហ្នឹងពូស្គាល់ឈ្មោះទេ?

វឿនៈ ពីណា?

វ៉ាស៊ីៈ អ្នកយោលអង្រឹងយាមពូហ្នឹង?

វឿនៈ ឌុច មេគេតែហ្នឹងហ្នឹងៗ វាយាមផ្ទាល់ខ្លួនវាៗ វាចងអង្រឹងជាប់ដើមកណ្តាលទៀត ខ្ញុំស្គាល់ច្បាស់ណាស់ៗ អត់ឆាកទេ នៅចាំមើលហ្នឹងៗ បើសិនជាវាយាមខុសបន្តិចក៏ខ្ញុំអាចកាត់ខ្សែរត់ដែរពេលហ្នឹងនោះ ប៉ុនវាផ្ទាល់ហើយកាំភ្លើងម៉ាដើម ៗ

ឃិនៈ ឥឡូវអញ្ចេះណាស៎ ខ្ញុំសុំសួរបន្តិច មន្ទីរសួរចម្លើយដែលមាននៅក្នុងហ្នឹងទាំងអស់មានប៉ុន្មាន?

វឿនៈ កន្លែងសួរចម្លើយមានម៉ាកន្លែង ប៉ុនវាគ្រាន់បែងចែករបស់វាបីកន្លែងៈ ១) ឌុចៗ ២) ចាន់ យើងថា ចាន់ខ្លង់នោះណា៎ អាហ្នឹងមួយក៏ដូច ឌុច ដែលវាស្មើគ្នាអត់មានអាណាខ្សែម៉ាខាងទេ

អាហ្នឹងមេចំហើយ ហើយមៅមាន ប៉ុន ដែលថាវ៉ៃចោលហ្នឹង ។ ប៉ុន មៅបាន ៥០ ។ មានតែ បួនហ្នឹងទេ ។

យិនៈ មិនមែន៧ ៨កន្លែងទេណោះ?

វឿនៈ ប៉ុនកន្លែងសួរចម្លើយមានតែ ៥០ និងនេះហ្នឹងអត់អីទេ ។ ប៉ុន្តែ ខុច ហើយនឹង ចាន់ អត់បាន ទេ វ៉ៃហើរដើង ចងសុទ្ធតែញូរដើង ។ នេះខ្ញុំឃើញដាក់ស្ដែងហ្នង ។

យិនៈ គុកដែលដាក់អ្នកទោស ដែលបងសរុបទៅមើលឃើញប៉ុន្មាន គុកក្នុងដី?

វឿនៈ គុកក្នុងដីមាន៤

រ៉ាស៊ីៈ ហើយក្នុងមាកន្លែងប៉ុន្មាននាក់?

វឿនៈ នៅជិតៗគ្នាអញ្ចឹង បែរគ្នាអញ្ចឹងហ្នង ពីមាកន្លែងៗអញ្ចឹងហ្នង ហើយអារណ្ដៅមួយធំ អាហ្នឹង សម្រាប់អ្នកទោសដែលយកពីឆ្ងាយៗមៅ ឬមួយយកពីណាពីណីមៅច្រើន វាយកទៅដាក់អា រណ្ដៅធំ ។ នៅពេលសួរចម្លើយហើយបានយកមកដាក់អាតូចៗនេះ ។

យិនៈ រណ្ដៅធំហ្នឹងវានៅក្នុងដីជម្រៅប៉ុន្មាន?

វឿនៈ ជម្រៅប្រហែលជា ៣-៤ម៉ែត្រ ។

យិនៈ ដាក់ពេញទៅ?

វឿនៈ អត់ពេញទេបង ។ ដាក់តាមចំនួនបានប៉ុន្មានដាក់ប៉ុណ្ណឹង ។

យិនៈ ហើយសួរចម្លើយនៅត្រង់ណា?

វឿនៈ ចេញពីរណ្ដៅមៅ យកមកសួរចម្លើយឯក្រៅណោះ ។

យិនៈ អញ្ចឹងអាដាក់ចូលហ្នឹងជណ្ដើរ ឬក៏យោង?

វឿនៈ ជីកដីធ្វើជណ្ដើរដែរ ។ ដល់ពេលខ្លះទៅបានគេដាក់ជណ្ដើរអាសីចុះ ។

យិនៈ ចុះបងពេលដែលទឹកឡើងជិនន់ហើយ ទៅលិចអ្នកទោសងាប់អស់ហ្នឹង មានឃើញផ្ទាល់ភ្នែកឆ្នាំ ណាទេ?

វឿនៈ ឃើញ ប៉ុនអត់បានចាំឆ្នាំ ប៉ុនងាប់អ្នកទោសអស់ច្រើនណាស់ ។ វាទឹកជន់មៅ យប់អត់ដឹង មៅភឹបៗអញ្ចឹង កងការពារ ខ្ញុំក៏នៅនោះដែរ ។

យិនៈ មានអ្នកទោសរួចខ្លះទេ?

វឿនៈ អ្នកទោសរួចខ្លះ ងាប់ច្រើន ។ ងាប់វាជាប់នៅដោះមិនបាន ។ ឯអ្នកកងការពារនោះ អាខ្លះឡើង ចុងឈើ ។ ហ្នឹងអ្នកទោសស្លាប់ថ្ងៃហ្នុងក៏ច្រើនដែរ ។

យិនៈ អាកងការពារម៉េចក៏វាឡើងចុងឈើវាខ្លាចលិចទឹកងាប់?

វឿនៈ ខ្លាចស្លាប់ ព្រោះអាអ្នកទោសវាជាប់ខ្នោះម៉េចទៅហ៊ានដោះ ។ ដោះខ្លាចគេថាអី ។

យិនៈ អូរបើគ្មានបញ្ហាអត់ហ៊ានដោះទេ?

វឿនៈ បាទ! តែដល់ទឹកលិចហើយ ចេះតែឡើងយកតែរួចខ្លួនទៅ ។

ពាំស៊ីៈ ហើយចុះពេលហ្នឹង ឌុច នៅឯណាដែរទៅ?

វឿនៈ ឌុច នៅហ្នុងដែរ ។ ឌុច ក៏ឡើងចុងឈើដែរ ។

យិនៈ បើអញ្ចឹងលិចតាំងកន្លែង ឌុច អីតាំងអស់?

វឿនៈ ចុះបើជាប់គ្នាអញ្ចេះ ។ ជាប់តាំងអស់ កន្លែងអ្នកទោសអញ្ចឹង កន្លែង ឌុច នៅហ្នឹងទៅហើយ អត់មានទៅណា ។ វានៅជាមួយអ្នកទោស ។

ពាំស៊ីៈ ពូអាចគូរដាក់ក្រដាស់បន្តិចបានទេពូ ខ្ញុំចង់ឲ្យពូគូរ ឧទាហរណ៍ថាកន្លែងមន្ទីរធំវានៅត្រង់ណា ហើយអាមន្ទីរ ឌុច ត្រង់ណា ហើយមន្ទីរ ចាន់ ត្រង់ណា?

វឿនៈ អត់ទេ! ជាប់គ្នាហ្នឹង ។

( វឿន បានគូរបញ្ជាក់ពីទីតាំងមន្ទីរ-១៣ដាក់ក្រដាស)

យិនៈ អានេះផ្លូវចូលពីអាយអ្ហេះ?

វឿនៈ ក្នុងរបងគុកអញ្ចឹងដែរ........ កន្លែងវាអត់មានផ្ទះអីទេ ចង់អង្រឹងដេកអីទេ ។

យិនៈ ចុះបើមានភ្លៀងមៅ តើ ឌុច ហ្នឹងទៅណា?

វឿនៈ ឌុច វាមានផ្ទះវានៅក្នុងដី ។

យិនៈ ឌុច វាមានផ្ទះនៅក្នុងដី!

វឿនៈ បាទ! ផ្ទះនៅក្នុងដី អាមួយចូលទៅក្នុងមាត់ស្ទឹងអញ្ចេះនេះ ។ ដីវាដីអស់តាស់ហើយវាចាក់ បាន អីភ្លៀងចូលរួច ។ វាធ្មើអញ្ចឹងទៅធ្លាយមាត់ស្ទឹងណោះ ។ ហ្នុងផ្ទះវាហើយក្នុងដីហ្នុង ។

ពាំស៊ីៈ អញ្ចឹងពូអានេះ មន្ទីរ ឌុច?

វឿនៈ បាទ!

ពាំស៊ីៈ អាហ្នឹងនៅខាងកើត លិច ត្បូង?

វឿនៈ នៅខាងលិច ។ មាត់ស្ទឹង ។

ពាំស៊ីៈ អានេះជើង ខាងណោះ អានេះត្បូង ។ ចុះអាបន្ទាប់ពីនេះមៅនេះ?

វឿនៈ អាហ្នឹងអ្នកទោស ។ រណ្តៅជាប់គ្នារហូត ។

ពាំស៊ីៈ ចុះមន្ទីររបស់ ចាន់ នោះ?

វឿនៈ ជាមួយគ្នាហ្នឹង បើគេចង់សួរអ្នកទោស មានបញ្ញាតិ ឌុច ហ្នឹងឲ្យយកពីរណ្ដៅណាក៏បានដែរ ឈ្មោះណាក៏បានដែរ ។

រ៉ាស៊ីៈ យកទៅសួរចម្លើយនៅត្រង់ណា?

វឿនៈ សួរចម្លើយ គ្រាន់តែយកពីរណ្ដៅមៅសួរ នៅលើគោក ។ អត់មានកន្លែងទេ ។

រ៉ាស៊ីៈ អានេះជារណ្ដៅហើយណោះបង?

វឿនៈ បាទ! ហ្នឹងហើយ ។

រ៉ាស៊ីៈ អញ្ចឹងអាកន្លែងនេះជាកន្លែងសួរចម្លើយ?

វឿនៈ បាទ! កន្លែងសួរចម្លើយ ។ ឧទាហរណ៍ថាចង់សួរឈ្មោះនោះមួយ ឲ្យកងការពារហ្នឹងចាក់សោរ យកមៅ ឲ្យវាសួរទៅ ។

រ៉ាស៊ីៈ អញ្ចឹងកន្លែងសួរចម្លើយនៅខាងត្បូងអេ្ហះ?

វឿនៈ បាទ! នៅកៀនដីបូកខាងត្បូង ។

រ៉ាស៊ីៈ ហើយចុះត្រពាំងប្រាបនោះនៅត្រង់ណាដែរ?

វឿនៈ ត្រពាំងប្រាប់នៅខាងជើងណោះទេ រួចមន្ទីរវានៅមាត់ស្ទឹងណោះទេ ។

ឃិនៈ រួចពុថាខាងមាត់ស្ទឹងខាងជើងម៉ាជួរនេះក៏មានដែរ ហើយមាត់ស្ទឹងខាងត្បូងក៏មានដែរ?

វឿនៈ អត់ទេ! មានតែម៉ាកន្លែងទេ ។

ឃិនៈ នៅខាងត្បូងមាត់ស្ទឹងអ្ហាស់?

វឿនៈ បាទ!

ឃិនៈ ចុះអាកន្លែងវ៉ៃចោលនៅត្រង់ណា អណ្ដូងជ្រៅៗ?

វឿនៈ អាកន្លែងខ្ញុំប្រាប់បងឯង អាកន្លែងខ្ញុំដេញឈ្លូសជួបហ្នឹង ខាងត្បូងស្ទឹងណោះ ។ សួរពួកម៉ាកខ្ញុំទៅដឹងហើយ មៅដេញឈ្លូស ។ មៅដល់ហ្នឹងបាញ់ចាប........ប៉ុនៅក្នុងមន្ទីរហ្នឹងតែមួយទេ អត់មានបែងចែកអីទេ ឌុច ក៏ហ្នឹង ចាន់ ក៏ហ្នឹង ប៊ុន ក៏ហ្នឹង ហើយអីមួយទៀតនោះ ផល ក៏ហ្នឹងដែរ ។

ឃិនៈ ចុះថា មាសៗ ដៃដល់ណាស់នោ?

វឿនៈ មាស ហ្នឹងហើយដៃ របស់គេជាមួយ ឌុច ។ ប៊ុន មាស ហ្នឹងស្លាប់បាត់ហើយ ។

ឃិនៈ មាស ផល ប៊ុន!

វឿនៈ ផល ប៊ុន ហ្នឹងអត់អីទេ ខ្ញុំចាត់ទុកថាល្អហ្មង ។

ឃិនៈ អញ្ចឹងបានដល់ក្រោយម៉ោ ឌុច ត្រូវវ៉ៃពីរនាក់ហ្នឹងចោល!

វឿនៈ បាទ! ល្អណាស់ អ្នកទោសមិនដែលត្រូវមាំរំពាត់ទេ គ្រាន់តែសួរតែមាត់ៗទេ មិនដែលដៃជើងដល់ទេ ។

ភាស៊ីៈ គេសួរថាម៉េចខ្លះទៅ?

វឿនៈ គេសួរតាមរឿងរ៉ាវគេ ។

ឃិនៈ យ៉ាងម៉េចក៏មិនវ៉ៃដែរណោះ?

វឿនៈ អត់វ៉ៃទេ ។ ប៉ុន និង ផល អត់ដាច់ខាតមិនដែលវ៉ៃ ទៅសួរកន្លែងណាក៏អត់ឃើញវ៉ៃដែរ តែបើតា ឌុច សួរហ្មងដឹងហើយបង ។

ឃិនៈ ចុះពីរនាក់ហ្នឹងមានដឹងថាកំហុសអីបានជាគេយកគាត់ទៅវ៉ៃចោល?

វឿនៈ ខ្ញុំអត់ដឹងដែរ ស្រាប់តែយកគ្នាទៅវ៉ៃចោលបាត់ទៅ ។

ភាស៊ីៈ នៅឆ្នាំណាដែរវ៉ៃហ្នឹង?

វឿនៈ នៅឆ្នាំ ៧៣ ។

ឃិនៈ ឥឡូវខ្ញុំសុំសួរចំណុចចុងក្រោយមួយ ចំនួនរណ្ដៅពូបាននិយាយហើយ កន្លែងសម្លាប់អី ខ្ញុំចង់សួរប្រភេទអ្នកទោសដែលគេយកមកដាក់ហ្នឹង តើមើលពូសង្កេតឃើញមានអ្នកទោសច្រើនជារបៀបទាហាន កម្មាភិបាលខ្មែរក្រហម ឬក៏ស្អីណាខ្លះដែលពូដឹងពូស្គាល់ មើល៍សូមរៀបរាប់ត្រង់បន្តិចមើល?

វឿនៈ ខ្ញុំវាមិនសូវបាននៅហ្នឹងជាប់ផង កាលនោះខ្ញុំមៅ មៅទៅជួនកាលឃើញច្រើន ជួនកាលឃើញតិច ។

ឃិនៈ អ្នកហ្នឹងស្លៀកពាក់របៀបម៉េច មានស្រី មានប្រុសអីដែរទេ?

វឿនៈ មានតាំងពីកូនក្មេងដែរ ។

ឃិនៈ ស្លៀកពាក់ មានស្លៀកខ្មៅដែរអី?

វឿនៈ មានស្លៀកពាក់អាវទាហាន ។

ឃិនៈ ឆ្នាំណា?

វឿនៈ ៧៣ហ្នឹង ។

ឃិនៈ អូរមុនបែកហើយអាហ្នឹង ជាទាហាន ដែលជាឈ្លើយសឹកហើយអាហ្នឹង?

វឿនៈ បាទ! ដឹងអី ។

ឃិនៈ ទាហានលន់ ណុលហ្នឹង?

វឿនៈ បាទ! ជួនកាលជាប្រជាជនយើងហ្នឹងដែរ ។

យិនៈ ប្រជាជនយើងជនបទ មូលដ្ឋានហ្នឹង?

វឿនៈ បាទ! មូលដ្ឋាននេះនៅម្តុំនេះ ដូចខ្ញុំថាដែលគេយកអីៗទៅឲ្យបងប្អូនគេហ្នុង ។

យិនៈ អូរ! យល់ហើយ ។ ដូចក្មួយអីនគរបាលថាឪពុកគាត់ធ្វើស្មៀនអីហ្នឹង ស្មៀនសាលាស្រុក ។

វឿនៈ ហើយ រត្ន័ ហ្នឹងក៏យកទៅដែរ ។ ប៉ុនគ្រាន់តែខ្ញុំអត់បានមៅទេ យកបងទៅហ្នឹង ។

រ៉ាស៊ីៈ នៅក្នុងរយៈពេលដែលពូចូលទៅធ្វើការនៅហ្នឹង ហើយក្រោយមៅពូបានជាប់គុកនៅហ្នឹង តើពូមានដឹងថា ឌុច បានសម្លាប់មនុស្សប៉ុន្មាននាក់ ឬក៏ធ្វើទារុណកម្មមនុស្សប៉ុន្មាននាក់?

វឿនៈ ខ្ញុំអត់បានដឹងតែហ្នុង កាលហ្នឹងខ្ញុំដឹងតែប៉ុណ្ណឹង ។

រ៉ាស៊ីៈ បាទ! អានេះខ្ញុំចង់រយៈពេលដែលពូធ្វើការនៅហ្នឹង នៅក្នុងអំឡុងឆ្នាំ ៧៣ ហ្នឹងអ្នាស់ តើពូបានឃើញ ឌុច ធ្វើទារុណកម្មដោយផ្ទាល់ភ្នែកពូប៉ុន្មានដង ហើយធ្លាប់ឃើញសម្លាប់ប៉ុន្មានដងដែរ?

វឿនៈ អាវៀងធ្វើទារុណកម្មនោះវា រាល់តែថ្ងៃរាល់យប់ ។

យិនៈ សឹង្កតែគ្រប់គ្នាសោះហើយ ។

វឿនៈ បាទ! ហើយអ្នកទោសទាំងប៉ុន្មានដាក់ទាំងអស់ ។ វៀងសម្លាប់ខ្ញុំឃើញតែម្នាក់ទេដែលបាញ់ម្នាក់ដែលចងបង្គោលនោះ ខ្ញុំឃើញផ្ទាល់ភ្នែក ។ អាវៀងដែលគេយកទៅសម្លាប់គេមិនឲ្យពួកខ្ញុំដឹងទេទាល់បក្ខជនគេដែលធ្លាប់ធ្វើការជាប់នឹងគេនោះ ។

យិនៈ អូរដែលគេហៅជនចម្រើនគេនោះ?

វឿនៈ ហ្នឹងហើយ ជនចម្រើនគេនោះ អាហ្នឹងបានដឹង ។ ម៉ាត្រឹមកងការពារពួកខ្ញុំនេះ គេអត់ឲ្យដឹងទេខ្លាចបែកការណ៍កន្លែងគេ ។

យិនៈ ពូអញ្ចេះ! ខ្ញុំចង់ឲ្យពូប្រាប់ឈ្មោះដែលថានៅក្នុងជនចម្រើននោះមានស្គាល់ឈ្មោះអីខ្លះ?

វឿនៈ ក្នុងជនចម្រើនហ្នឹងមានឈ្មោះ សឿង នោះមួយ ។

យិនៈ នៅរស់ទេ?

វឿនៈ នៅរស់ទេ ។

យិនៈ នៅឯណា?

វឿនៈ នៅភូមិគោក នេះ ។ សឿន ហើយនឹង ចេវ ។

យិនៈ ចេវ ហ្នឹងនៅឯណាដែរ?

វឿនៈ ចេវ ហ្នឹងស្លាប់បាត់ហើយ ។

យិនៈ ចុះ ណិន?

វឿនៈ ហ្នឹងហើយ ណិន ហ្នឹងមួយនៅទំនាប (ភូមិទំនាប) ។

យិនៈ ប៉ុន្តែជនចម្រើនដែរណោះ?

វឿនៈ ជនចម្រើនដែរ ។

រ៉ាស៊ីៈ មានឈ្មោះអីទៀតពូ?

វឿនៈ ខន យើងអាខនក្រញ៉ាញ់នេះ

**ផ្នែក «១»**

យិនៈ ៨ឆ្នាំ ១០ឆ្នាំ ១២ឆ្នាំ វ៉ៃដែរ?

វឿនៈ ហ្នឹងហើយ ។

យិនៈ ថា តាឌុច ហ្នឹងច្រើនប្រើក្មេងឲ្យវ៉ៃ មែនទេ មានឃើញផ្ទាល់ភ្នែកដែរ?

វឿនៈ អត់ដែលឃើញដែរ ។

យិនៈ ច្រើនប្រើក្មេងហ្នឹងឲ្យវ៉ៃ ប៉ុនអាក្មេងហ្នុងវ៉ៃមិនស្លាប់ទេ! វ៉ៃអនអញ្ចឹងទៅ បានមានឈ្មោះនេះ អាណិន, ស៊ុន, ខន បន្ថែម ។ មានអញ្ចឹងដែរទេ?

វឿនៈ ហ្នឹងហើយ មាន ។ ត្រឹមកងការពារខ្ញុំនេះមិនដឹងរឿងអីទេ...................ខ្ញុំឃើញប៉ុណ្ណឹង ។

រ៉ាស៊ីៈ ចុះនៅក្នុងឆ្នាំ១៩៧៣ហ្នឹង ពូបានដឹងថាមានជនចំរើនហ្នឹងមានប្អូននាក់ហ្នឹងអ្ហេះ?

វឿនៈ បាទ!

រ៉ាស៊ីៈ ចុះកងការពារ តើមនុស្សដែលស្ថិតក្នុងកងការពារ....

វឿនៈ ខ្ញុំស្គាល់គេអត់អស់ទេ ស្គាល់តែប៉ុន្មាននាក់ទេ ។

រ៉ាស៊ីៈ បាទ! ហើយមនុស្សដែលនៅក្នុងជនចំរើនហ្នឹងមានវ័យខុសគ្នាដែរអ្ហេះ?

វឿនៈ បាទ! មានចាស់ មានក្មេង ។

រ៉ាស៊ីៈ ចុះនៅក្នុងកងការពារនេះ?

វឿនៈ កងការពារគេដាក់សុទ្ធតែកុមារទេ ។

រ៉ាស៊ីៈ ជនចំរើននេះបាន..

វឿនៈ ជនចំរើននេះបានមានលាយចាស់ លាយក្មេងដែរ ។

រ៉ាស៊ីៈ ចុះអ្នកដែលនៅក្រោមបង្គាប់តា ឌុច ដូចជា ប៉ុន ផល ចាន់ អាហ្នឹងគេហៅជនអីវិញ?

វឿនៈ ហ្នឹងគេហៅម៉េចទេ ដូចថាដៃស្តាំរបស់គេទៅណា ។ អត់ពី ឌុច ទៅគេមៅជំនួស ឌុច ។ អត់អី ឌុច ទៅមាន ចាន់ ។ អត់ពី ចាន់ ទៅមាន មាស ហ្នឹងហើយ ។

រ៉ាស៊ីៈ មាន ប៉ុន មានអីដែរ?

វឿនៈ ប៉ុន ផល អីហ្នឹង ។ ផល គេសម្លាប់ចោល ។

រ៉ាស៊ីៈ មូលហេតុអីបានជាគេសម្លាប់ចោល?

វឿនៈ មូលហេតុដែលមកពីធ្វើការ ខូចបែកការណ៍បានសម្លាប់ចោលទៅ ។ ផល ហើយនឹង ប៉ុន ហ្នឹង ស្លូតណាស់ ។

ឃិនៈ ហើយពួកហ្នឹងមិនមែនអ្នកដៃដល់សម្លាប់មនុស្សទេ?

វឿនៈ អត់ទេ គេគ្រាន់តែឲ្យសួរចម្លើយទេ អត់ហ៊ានវ៉ៃ អត់ហ៊ានមាត់ធំផង ។ វាបញ្ជាឲ្យអាបក្ខជនរបស់វាយកទៅសម្លាប់ គឺយកទៅហើយ ។

ឃិនៈ បើអញ្ចឹង ខ្ញុំថា ផល ហ្នឹងបែបជាមនុស្សដែលមានមនោសញ្ចេតនា មិនកាច ។

វឿនៈ បាទ! ផល ហើយនឹង ប៉ុន ហ្នឹងអត់ដែលឃើញសម្លាប់បងប្អូនណាទេ គ្រាន់តែសួរចម្លើយមិនដែលឃើញវ៉ៃទេ ។ និយាយធំៗហើយ ។ បើថា ឌុច និង ចាន់ អត់បានទេបង ដូចគ្នា ។

រ៉ាស៊ីៈ បាទ!

វឿនៈ ចាន់ និង ឌុច គឺថាប៉ុនគ្នា ។

រ៉ាស៊ីៈ តើពូយល់ថាម៉េចដែរចំពោះការគ្រប់គ្រងរបស់ ឌុច នៅមន្ទីរ១៣ ហ្នឹង ហើយមានការសម្លាប់មនុស្សអស់រាប់សិបនាក់អញ្ចឹង តើលោកពូយល់ថាការគ្រប់គ្រងរបស់ ឌុច ហ្នឹង ជាការគ្រប់គ្រងបែបយ៉ាងម៉េច?

វឿនៈ ដល់ខ្ញុំឃើញគាត់ធ្វើអញ្ចឹងណា ខ្ញុំអត់ចង់ហ៊ានមើលទៀតទេ ឃើញគាត់ឃោរឃៅអញ្ចឹពេក ។

រ៉ាស៊ីៈ អញ្ចឹងពូយល់ថា គាឌុច ហ្នឹងជាមនុស្សឃោរឃៅ?

វឿនៈ បាទ!

រ៉ាស៊ីៈ មានចំណុចត្រង់ណាខ្លះដែលបញ្ជាក់ថាគាត់ជាមនុស្សឃោរឃៅ?

វឿនៈ ឃោរឃៅត្រង់ថាវ៉ៃមនុស្ស ហើយសួរចម្លើយ វ៉ៃដុតគ្នាហើយសម្លាប់អញ្ចឹងមិនថាឃោរឃៅម៉េច! វាឃើញដាក់ស្នែងនឹងភ្នែក ។

ឃិនៈ ហើយពូឃើញរាល់ថ្ងៃអញ្ចឹងហ្នង?

វឿនៈ រាល់ថ្ងៃហ្នឹង ។ ប្រចាំថ្ងៃជាប់ ។

រ៉ាស៊ីៈ អញ្ចឹងមនុស្សដែលបានមកជាប់នៅក្នុងមន្ទីរ១៣ ហ្នឹងខ្ញុំយល់ថាមិនមែនជា ឌុច ជាអ្នកសម្លាប់ទាំងអស់ទេមែនទេ?

វឿនៈ មិនមែនទាំងអស់ទេ ប៉ុនគ្រាន់មានបញ្ជាពីគាត់ ។ បើអត់បញ្ជាមិនមែនមានមនុស្សស្លាប់ទេ ។

រ៉ាស៊ីៈ អញ្ចឹងបានន័យថាអ្នកដែលនៅក្រោមបង្គាប់របស់ តាឌុច ហ្នឹងពិតជាបានទទួលបញ្ជាពីតា ឌុច ហ្នឹង?

រឿនៈ បាទ! គាត់មិនបានសម្លាប់ដោយផ្ទាល់ដៃ ប៉ុនគាត់បញ្ជាកូនចៅហានដៃស្ដាំរបស់គាត់ហ្នឹង ។

រ៉ាស៊ីៈ អញ្ចឹងពូយល់ថា បើសិនជាការមានការរកខុស រកត្រូវ រកភាពយុត្តិធម៌ តើទោសកំហុសទាំងអស់ហ្នឹងត្រូវធ្លាក់ទៅលើអ្នកណា នៅក្នុងមន្ទីរ១៣ហ្នឹង?

រឿនៈ ធ្លាក់លើតា ឌុច ព្រោះមន្ទីរនេះជាមន្ទីររបស់ តាឌុច ។ មនុស្សបើថាចង់ឲ្យស្លាប់ៗដោយសារ តាឌុច ចង់ឲ្យរស់ៗក៏ដោយសារ តាឌុច ដែរ គឺនៅលើ តាឌុច ទាំងអស់ ។

រ៉ាស៊ីៈ បាទ! អញ្ចឹងពូចង់ឲ្យមានតុលាការកាត់ទោសគាត់ទេ?

រឿនៈ ចង់ ។

រ៉ាស៊ីៈ ដោយសារមូលហេតុប៉ុន្មានយ៉ាងរបស់ពូបានចង់ឲ្យមានតុលាការ?

រឿនៈ ចង់ឲ្យមានព្រោះគាត់សម្លាប់គេច្រើនពេក ។ ចង់ឲ្យតុលាការកាត់ទោសគាត់ ព្រោះដោយសារតែគាត់ហ្នឹង មិនមែនអស់មនុស្សតិចទេ ។

រ៉ាស៊ីៈ បើសិនជាមានតុលាការមែន តើពូចង់ឲ្យតុលាការកាត់ទោសគាត់តាមរបៀប ឬក៏លក្ខណៈយ៉ាងម៉េច? ចង់ឲ្យគាត់ទទួលទោសយ៉ាងម៉េចពីតុលាការ ដើម្បីឲ្យសមនឹងភាពយុត្តិធម៌ សមនឹងភាពការចង់បានយុត្តិធម៌របស់ប្រជាជន?

រឿនៈ ខ្ញុំចង់ឲ្យតុលាការកាត់ទោសគាត់តាមផ្លូវច្បាប់ ។

រ៉ាស៊ីៈ បាទ! តាមផ្លូវច្បាប់ ប៉ុន្តែនៅក្នុងចិត្តរបស់ពូ នៅក្នុងអារម្មណ៍របស់ពូ ដែលពូយល់ថា ឌុច ហ្នឹងជាមនុស្សឃោរឃៅ ជាមនុស្សសាហាវ តើពូចង់ដាក់ទោសគាត់យ៉ាងម៉េច?

រឿនៈ ចង់ឲ្យគាត់ជាប់គុកមួយជីវិតគាត់តែហ្មង ព្រោះគាត់ហ្នឹងធ្វើបាបគេណាស់ មិនត្រឹមតែគេ រហូតដល់ខ្ញុំ រហូតដល់គេស្អប់ខ្ញុំនេះទៀតរាល់ថ្ងៃ ។

រ៉ាស៊ីៈ គាត់ចាប់ពូដាក់គុកអញ្ចឹងពូខឹងគាត់ទេ?

រឿនៈ ខឹង ប៉ុនមិនដឹងធ្វើម៉េចគេទេ ។

រ៉ាស៊ីៈ ចុះឥឡូវនៅខឹងទៀតទេ?

រឿនៈ ឥឡូវនៅតែខឹងអញ្ចឹង ។ ឃើញសីឥតែសុំហើយ បំណាច់តែដាក់គុកខ្ញុំហើយ យកខ្ញុំទៅហើយធ្វើបាបធ្វើទោសខ្ញុំទៀត ។

រ៉ាស៊ីៈ ចុះប្រសិនបើឥឡូវពូបានជួបគាត់ តើពូហ៊ានធ្វើបាបគាត់ទេ?

វឿនៈ ហ៊ីន ។ ឲ្យតែឲ្យគឺដាក់ទាល់តែងាប់ឥឡូវ ធ្វើបាបខ្ញុំ ធ្វើបាបពួកមាកបងប្អូនខ្ញុំគគោកគដី ហើយខ្ញុំ ម៉េចហ៊ីនទៅតវ៉ានឹងគេ ។

វ៉ាស៊ីៈ ចុះបើសិនជាមានតុលាការហើយ តុលាការហ្នឹងកាត់ទោសគាត់ អារម្មណ៍របស់ពូអស់ចិត្តទេ គំនុំទាំងប៉ុន្មានបានរសាយទេ?

វឿនៈ អស់ចិត្ត ឲ្យតែតុលាការកាត់ទោសគាត់ ខ្ញុំអស់ចិត្តហើយ ។ រាល់ថ្ងៃនេះឲ្យទេជួប ហើយអង្គការថាអ្អែងហ៊ីនទេម្នាក់ហ្នឹងធ្លាប់ធ្វើបាបអ្អែង អ្អែងនៅហ្នឹងដែលស្គាល់មុខទេ ថាស្គាល់ឲ្យតែឲ្យដាក់ឥឡូវហើយខ្ញុំនេះ តាមខឹងនេះ វាពេកទៅហើយ ។

វ៉ាស៊ីៈ ពូមានអីចង់បន្ថែមជាងហ្នឹងទៀតទេ ពីមន្ទីរ១៣ ដែលខ្ញុំអត់ទាន់បានសួរ?

វឿនៈ អត់ទេ! បើខ្ញុំ នៅមិនសូវបានជាប់................ ។

វ៉ាស៊ីៈ នៅឆ្នាំណាដែលពូចេញពីមន្ទីរ១៣ហ្នឹង?

វឿនៈ ចូល ៧៣ ហ្នឹងអត់ទាន់បានម៉ាឆ្នាំផង ខ្ញុំរត់ចេញវិញទេ ។

វ៉ាស៊ីៈ មិនមែនគេដោះលែងទេអ្ហេះ?

វឿនៈ អត់ដោះទេ ខ្ញុំលែងអ្នកទោសបីនាក់នោះ ។

វ៉ាស៊ីៈ ដល់លែងអ្នកទោសហើយ ពូជាប់ទោសវិញ?

វឿនៈ ជាប់គុក ។

វ៉ាស៊ីៈ ជាប់គុកបានប៉ុន្មានខែបានគេបញ្ជូនទៅវិញ?

វឿនៈ រត់ហើយគេបញ្ជូនខ្ញុំទៅវិញទៅ ។ បញ្ជូនទៅវិញ បានខ្មោចតាហម និងសោម ទៅយកខ្ញុំវិញ ។ ទៅយកមៅមៅនៅសហករណ៍ឯណេះវិញ កុំអីខ្ញុំងាប់ហ្នុងបាត់ហើយ

**ប្រធានឃុំអមលាំងៈ** មន្ទីរហ្នឹងអត់មានសូវនៅវែងប៉ុន្មានទេ ព្រោះខ្ញុំនៅនេះដែរ មន្ទីរហ្នឹងនៅរយៈពេលខ្លី ព្រោះ ឌុច ហ្នឹងគាត់ឆៅណាស់ មនុស្សគាត់សាហាវណាស់ ។

វឿនៈ អ្នកធ្វើការជាមួយវាឲ្យតែខុសសុទ្ធតែងាប់ហើយ គ្រាន់តែខ្ញុំហ្នឹងកុំរត់ចេញហើយ កុំប្រធានភូមជានាក៏ខ្ញុំងាប់ដែរ ប៉ុនបានគាត់ ។ អត់ស្រាយប្រវ៉ាក់ទេ ទោះទឹកលិចម៉េចក៏អត់មិនដោះអ្នកទោសដែរ ម៉េចនឹងហ៊ីនដោះបើគេអត់បញ្ជាផង ខ្លាចងាប់ដែរ ។ ទឹកលិចបន្តិចម្តង១ កងការពារឡើងចុងឈើអស់ទៅហើយ ។ អ្នកទោសគ្នានៅវាលនៅក្នុងរណ្តៅហ្នឹង ។ ................................

.......... (វឿន ដដែកជាមួយអធិការរងប៉ូលីសស្រុកថ្ពង) ។ ហ្នុងហើយ១ សុទ្ធតែអ្នកទោសនាំទៅកាប់នៅកន្លែងដីស្រែខាងជើងនោះវាលអស់ហើយ ហើយអាទំនប់ត្រពាំងទឹងខ្ញុំលើកនោះឥឡូវបាក់អស់ហើយ ។ នោះហើយដែលខ្ញុំលែងអ្នកទោសនៅទំនប់ត្រពាំងទឹងនោះហើយ ។

ភាំស៊ីៈ  ទំនប់អីគេ?

វឿនៈ គេហៅទំនប់ត្រពាំងទីង ប៉ុនដាក់ទំនប់អ្នកទោសក៏ត្រូវដែរ ប៉ុនគេហៅទំនប់ត្រពាំងទីងអញ្ចឹង ។

ភាំស៊ីៈ ទំនប់ហ្នឹងនៅត្រង់ណាអញ្ចេះ ខ្ញុំទៅដូចអត់?

ឃិនៈ អាហ្នឹងកន្លែងសម្លាប់អ្ហេះ?

វឿនៈ អត់ទេ! កន្លែងចេញធ្វើការ ។ កន្លែងធ្វើការកាប់ដី លើកទំនប់ហ្នុងហើយ ។

ភាំស៊ីៈ នៅជិតត្រពាំងប្រាបហ្នឹងដែរទេអ្ហេះ?

វឿនៈ បាទ! ហ្នុងហើយ ខាងជើងបន្តិច ។

ឃិនៈ ហើយចម្ការគេនៅក្បែរៗខាងនេះ?

វឿនៈ ចម្ការគេនៅស្រែជញ្ជូន...............

ឃិនៈ  វាលខ្ពស់ៗហ្នឹងអី?

វឿនៈ បាទ! វាលដីខ្ពស់ ដីខ្សាច់ហ្នឹង ។

ឃិនៈ ដាំដំឡូងល្អណាស់មើលទៅ!

វឿនៈ បាទ! ដំឡូងប៉ុនៗកំភួនជើង ។

ឃិន ប៉ុនអត់ឲ្យអ្នកទោសហូបទេអញ្ចឹង?

វឿនៈ គ្រាន់កងការពារដើរទៅបង្ហើបលួចមាំមើមបាន ហើយលុបដីទៅវិញទៅ ។ បើលួចញឹកញាប់គេសង្ស័យរករឿងដែរលែងហ៊ាន ។

ភាំស៊ីៈ  ពេលហ្នុងហូបបាយប្បបរ?

វឿនៈ ឌុច ហូបបាយ តែកងការពារហូបបបរ ។ គ្រាន់អ្នកទោសហូបបាយនឹងចាន អ្នកទោសហូបបាយនឹងបំពង់ទឹកត្នោតយើងហ្នឹង ។ ដាក់បបរ ។

ឃិនៈ ប៉ុនបបរដូចគ្នា?

វឿនៈ បបរដូចគ្នា លាយជាមួយបាយ លាយឆ្នាំងតូចមួយ មានប្រពន្ធ គាចាន់ ជាអ្នកធ្វើសេដ្ឋកិច្ចហើយកាលនោះ ។

ភាំស៊ីៈ ចុះ គាឌុច នោះ?

វឿនៈ ហ្នឹងហើយដាំឲ្យគា ឌុច និងប្តីគេ បីនាក់ហ្នឹងទេ ។

ភាំស៊ីៈ ប៉ុន ផល អីម៉េចដែរ?

វឿនៈ ប៉ុន ផល អីបាយដែរ ប៉ុនដល់ហើយហ្នឹងបាត់ឈ្មោះទៅ យកទៅសម្លាប់តាំងពីនេះបាត់ហើយ អត់បាននៅប៉ុន្មានផង ។ មិនដឹងបញ្ជូនពីណាមៅ ផល ហើយនឹងប៉ុន ហ្នឹង ។ ឃើញបានប្រហែល

កន្ទះខែចុះស្រាប់តែបាត់អត់ដឹងទៅណា ខ្ញុំអត់ដឹងថាគេសម្លាប់ផង ឥឡូវបានឮគេថា ប៉ុន ហើយនឹង ផល គេយកទៅវៃចោលបាត់ហើយ ។ ខ្ញុំចេញបាត់ហើយមានដឹងណា ពេលដែលខ្ញុំមោខ្ញុំនៅហ្នុងឡើយទេ ។

រ៉ាស៊ីៈ អញ្ចឹងអរគុណពូច្រើនពូ!

វឿនៈ បាទ!

ឃិនៈ សូមអរគុណណាស់!ក្នុងការសម្ភាសន៍លោកពូរយៈប៉ុន្មានម៉ោងនេះ គឺបានទទួលពត៌មានល្អដល់ខ្ញុំណាស់ ។ សូមអរគុណ ។

វឿនៈ បាទ!

---